## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### កំណត់ហេតុ
### ស្តីពីការសម្របសម្រួលការព្យួរកិច្ចសន្យាការងារ
### នៅ ក្រុមហ៊ុន ធី វ៉ាយ ហ្វេសិន (ខេមបូឌា) T Y FASHION (CAMBODIA) PLC

ថ្ងៃសុក្រ ៧កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ដប់បួន និងសាបសិបនាទីគត់ មានកិច្ចប្រជុំស្តីពី **ការសម្របសម្រួលការព្យួរកិច្ចសន្យាការងារ ជូនកម្មករនិយោជិត ចំនួន ១០០** នាក់ ស្រី ៦២នាក់ លើកម្មករនិយោជិតសរុបចំនួន **៣៤៧០**នាក់ ស្រី **២៩៨០**នាក់ នៅ ក្រុមហ៊ុន ធី វ៉ាយ ហ្វេសិន (ខេមបូឌា) T Y FASHION (CAMBODIA) PLC ដែលមានអាសយដ្ឋាននៅ ភូមិស្រះពោធិ៍ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ក្រោមអធិបតីភាព **ឯកឧត្តម ធុល នាង** ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។ **ក្នុងនោះមានសមាសភាពចូលរួមដូចខាងក្រោម៖**

**I. តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល**

| | |
|---|---|
| ១.លោក ស្រី សិរីវឌ្ឍនា | អនុប្រធានមន្ទីរ |
| ២.លោក ប៊ុនថន ភារម្យ | មន្ត្រី |
| ៣.លោក ឡាយ វណ្ណរ័ត្ន | មន្ត្រី |

**II.ភាគីតំណាងក្រុមហ៊ុន**

| | |
|---|---|
| ១.លោក ចេន ណេន | ទីប្រឹក្សាផ្នែកច្បាប់ និងមន្ត្រីដោះស្រាយវិវាទការងារប្រចាំក្រុមហ៊ុន |
| ២.លោក សេក សុខ | ប្រធានរដ្ឋបាល |

**III.ភាគីតំណាងកម្មករនិយោជិត សហជីព**

កម្មករនិយោជិតដែលត្រូវបានព្យួរកិច្ចសន្យាការងារទាំង១០០នាក់ ដោយមានការស្នើសុំរបស់កម្មករនិយោជិត ពី៥០% ក្នុង០១ខែ នៃប្រាក់ឈ្នួលអប្បរមា ១៩៤ដុល្លារ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ។ បន្ទាប់ពីមានការជជែកពិភាក្សាគ្នាជាមួយក្រុមហ៊ុន ក្រោមការសម្របសម្រួលរបស់ប្រធានអង្គប្រជុំ កម្មករបានស្នើតួលេខលើកទី២ចំនួន៨០ដុល្លារក្នុង១ខែ អំឡុងពេលព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។

**IV.យោបល់ឯកឧត្តមប្រធានអង្គប្រជុំ**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ធុល នាង** ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានបើកកិច្ចប្រជុំ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីតំណាងក្រុមហ៊ុន អាជ្ញាធរមានសមត្ថកិច្ច និងភាគីតំណាងកម្មករនិយោជិត ដែលបានអញ្ជើញចូលរួមប្រជុំនៅក្នុងថ្ងៃនេះ ក្រុមហ៊ុនមានការស្នើសុំរបស់ទៅក្រសួងការងារដើម្បីព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ផ្អែកតាមច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា ដោយសារតែក្រុមហ៊ុនមានការខ្វះខាតការបញ្ជាទិញ ហើយក្រុមការងារ មកដើម្បីអង្កេតការព្យួរកិច្ចសន្យាការងារ និងដើម្បីរៀបចំអោយមានកិច្ចព្រមព្រៀងរវាងកម្មករនិយោជិត និងក្រុមហ៊ុន នូវអត្ថប្រយោជន៍ដែលក្រុមហ៊ុនផ្តល់ជូនក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងាររយៈពេល០២ខែនេះ។ ស្ថិតក្រោមការសម្របសម្រួលរវាងកម្មករនិយោជិត និងតំណាងក្រុមហ៊ុន ឯកឧត្តមប្រធានអង្គប្រជុំបានស្នើតួលេខសម្រាប់ធ្វើការពិចារណារបស់ក្រុមហ៊ុន និងកម្មករនិយោជិតដើម្បីទទួលបានកិច្ចព្រមព្រៀងរួមមួយអាចអនុវត្តទាំងអស់គ្នា។

Scanned with CamScanner

## V. យោបល់ក្រុមហ៊ុន

ដោយក្រុមហ៊ុនជួបវិបត្តការបញ្ជាទិញផលិតផល ទើបមានការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន១០០នាក់ ស្រ្តី៦២នាក់ ដោយក្រុមហ៊ុនផ្តល់ជូននូវអត្ថប្រយោជន៍ចំនួន៦០ដុល្លារ ដោយចាប់ផ្តើមតម្លើងពី៣០ដុល្លារ ជូនកម្មករនិយោជិត។ ជាបន្ទាប់ពីមានការជជែកជាថ្មីក្រុមហ៊ុនបានស្នើតួលេខអត្ថប្រយោជន៍រហូតដល់៧០ដុល្លារ ក្នុង១ខែ អំឡុងពេលព្យួរកិច្ចសន្យាការងាររយៈពេល២ខែ តាមការស្នើសុំរបស់ប្រធានអង្គប្រជុំ។ ក្រុមហ៊ុនបានបញ្ជាក់ថាអស់លទ្ធភាពក្នុងការផ្តល់ជូនលើសពីនេះមិនបានឡើយ។

## VI. លទ្ធផលនៃការសម្របសម្រួល

- ក្រុមហ៊ុនព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន១០០នាក់ ស្រី៦២នាក់ ចាប់ពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០២២ រហូតដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២។ កម្មករនិយោជិតឯកភាព
- ក្រុមហ៊ុនផ្តល់ជូនអត្ថប្រយោជន៍ចំនួន៧០ដុល្លារក្នុង១ខែ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងាររយៈពេល០២ខែ (សរុបទឹកប្រាក់ទទួលបាន១៤០ដុល្លារ អំឡុងពេលព្យួរកិច្ចសន្យាការងារ) ចាប់ពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០២២ រហូតដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២។ កម្មករនិយោជិតបានឯកភាពទទួលយកនូវអត្ថប្រយោជន៍ដែលបានផ្តល់ជូនក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ។
- ប្រាក់អត្ថប្រយោជន៍ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងាររយៈពេល០២ខែ នឹងបើកជូនកម្មករនិយោជិតប្រចាំខែជារាងរាល់ថ្ងៃទី១០ នៃខែបន្ទាប់។

កំណត់ហេតុ ចប់សព្វគ្រប់នៅវេលាម៉ោង ដប់ប្រាំពីរកត់ នាថ្ងៃខែឆ្នាំដដែល។

**ភាគីតំណាងក្រុមហ៊ុន** | **ភាគីតំណាងកម្មករ** | **អ្នកធ្វើកំណត់ហេតុ**

HRD
TY FASHION (CAMBODIA) PLC

ឡាយ វណ្ណារ័ត្ន

**ប្រធានអង្គប្រជុំ**

ធុល នាង

13387. 5169 5610 5651.
14140 13615 8896. 17759. 19904
3361. 21807. 3154 3257. 24021.
21568. 22216. 12494. 17730. 25916.
26692 26408 21878. 19089. 19861 22444 26337.
26578 25948 19936. 25988 17797. 18618. 26853.
26084 25978 25996 25393 24881 26921 26905
25530 25598 26784 26832 26404 26348 26251
26539 24531 24184 25441 25474 25048 26858

Scanned with CamScanner

សូមមេធាវីជួយកិច្ចសន្យាការងារ
ក្រុមហ៊ុន ជី ម៉ាយ ហ្វេសិន ខេមបូឌា

25384 25570 25574

26172 26914 26177 21128

26434 26542 26820 24903 26667 26984 24948

26596 26631 25147 26086 26111 26590 24900

20827 8444 21218 21150 21183 21125 23248